# អនុក្រឹត្យលេខ ១៨ អនក្រ

## ស្តីពីឯកសណ្ឋានបច្ចេកទេស និង ទង់ជ័យកងយោធពលខេមរភូមិន្ទ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- យោងតាមក្រឹត្យ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីសញ្ញាឋានន្តរសក្តិ នៃ កងទ័ពជាតិ
- យោងតាមក្រឹត្យ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីរូបភាពលំដាប់សក្តិ នៃកងទ័ពជាតិ
- យោងតាមក្រឹត្យ លេខ ០៤ អនក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីឯកសណ្ឋាន និង ផ្លាកសញ្ញា នៃ កងទ័ពជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងការពារជាតិ ចុះថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ១៩៩៤
- យោងតាមសំណើ របស់អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ចុះថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ១៩៩៣

## សំរេច

**មាត្រា ១** ត្រូវបានរៀបចំឯកសណ្ឋានបច្ចេកទេសទ័ពជំនាញ ប្រភេទទ័ពជើងគោកដូចខាងក្រោម ÷

ក-<u>ឯកសណ្ឋានបច្ចេកទេសទ័ពរថក្រោះ រថពាសដែក</u> :

- ឯកសណ្ឋានធំលេខ ១.២.៣ ការងារ និង ឯកសណ្ឋានប្រយុទ្ធដូចទ័ពជើងគោក
- ឯកសណ្ឋានបច្ចេកទេសជំនាញ ក្រណាត់ត្រែអ៊ីពណ៌ខ្មៅ អាវដៃវែង ខោជើងវែង សំរាប់ពាក់ពេលធ្វើការងារបច្ចេកទេស ពេលបើកបរ ឬ នៅលើរថក្រោះ រថពាសដែក តែរថពាសដែក ឯកសណ្ឋានបច្ចេកទេសនេះអាចពាក់បានតែអ្នកបើក អ្នកបាញ់ និង [illegible] ចំពោះថ្មើរជើងលើពាសដែកគ្មានឯកសណ្ឋានបច្ចេកទេសទេ ម៉ូតកាត់ដូចឯកសណ្ឋានប្រយុទ្ធទ័ពជើងគោក ។ មួកបេរ៉េពណ៌ខ្មៅ ស្បែកជើងស្បែក ករវែងពណ៌ខ្មៅចងខ្សែ ស្រោមជើងពណ៌ខ្មៅ ។

ខ-ឯកសណ្ឋានបច្ចេកទេស កងទ័ពគ្រឿងយន្តវិស្វកម្ម និងអ្នកធ្វើការងារក្នុងរោងជាងជួសជុលបច្ចេកទេសគ្រឿងយន្តគ្រប់ប្រភេទ :

- ឯកសណ្ឋានបច្ចេកទេស ដូចឯកសណ្ឋានបច្ចេកទេសរថក្រោះ ថ្មេញពាសដែកដែរ តែគ្រឿងយន្តវិស្វកម្មពណ៌ខ្មៅ ហើយអ្នកធ្វើការនៅរោងជាងជួសជុល បច្ចេកទេសគ្រឿងយន្តផ្សេងទៀតពណ៌ខៀវទឹកប៊ិច ម៉ូតរបៀបប្រើប្រាស់ស្បែកជើងមួក ដូចឯកសណ្ឋានបច្ចេកទេសទ័ពរថក្រោះ រថពាសដែក ។

គ-ឯកសណ្ឋានទ័ពពិសេស និង ស៊ើបការណ៍ :

- ឯកសណ្ឋានធំ លេខ ១.២.៣ និង ឯកសណ្ឋានការងារដូចទ័ពជើងគោក ឯកសណ្ឋានជំនាញទ័ពពិសេស គឺ ជាឯកសណ្ឋានប្រយុទ្ធសំរាប់ពាក់ពេលប្រតិបត្តិការស៊ើក និង ចុះបេសកកម្មតាមកងឯកភាព ។
- រូបភាព និង ម៉ូត : ក្រណាត់ត្រែអ៊ីពណ៌ជាំរ៉ាក្រឡាធំ ២ សំរាប់ ម៉ូត និង របៀបប្រើប្រាស់ ដូចឯកសណ្ឋានប្រយុទ្ធទ័ពជើងគោក ។
- មួកបេរ៉េពណ៌ក្រហម មួកដែក មួកហាមធំ និង មួកហ៊ីរ្យកគីពណ៌ជាំរ៉ា ។
- ស្បែកជើងមាន ២ សំរាប់ គឺ ស្បែកជើងស្បែកពណ៌ខ្មៅ កវែង ចងខ្សែឬរូត និង ស្បែកជើងជំនាញទ័ពពិសេស ។

ឃ-ឯកសណ្ឋានបច្ចេកទេសពេទ្យយោធា :

- សំរាប់ពេលធ្វើការជំនាញ ព្យាបាលជំងឺ និង ក្នុងមន្ទីរពេទ្យ ឯកសណ្ឋានពណ៌ស ។
- រូបភាព និង ម៉ូត : ក្រណាត់តេតារុង អាវដៃខ្លីកបើក ហោប៉ៅតូចមួយនៅខាងលើឆ្វេង និងហោប៉ៅពីរធំនៅខាងក្រោមមានគំរប កាត់ស្រួងវែងដល់ជង្គង់ ខោជើងវែងពណ៌ស ចង្កេះរឹតមានហោប៉ៅក្រោយមួយគ្មានគំរប ។

ង- ឯកសណ្ឋានប្រយុទ្ធទ័ពការងារព្រំដែន :

- ឯកសណ្ឋានទ័ពការងារព្រំដែនលេខ ១.២.៣ ការងារដូចទ័ពជើងគោក តែឯកសណ្ឋានប្រយុទ្ធមានពីរសំរាប់ ម៉ូតដូចទ័ពជើងគោកពណ៌ជាំរ៉ាក្រឡាតូច មួកបេរ៉េ មួកហាមធំ និងហ៊ីរ្យកគីពណ៌បៃតងហ្វីឡាពណ៌ជាំរ៉ា ស្បែកជើងស្បែកកវែងពណ៌ខ្មៅចងខ្សែ ឬ រូត ឬស្បែកជើងម៉ៃហ្វិកអាមេរិក ។

ច-ឯកសណ្ឋានបច្ចេកទេសអយុត្តាយោធា :

- ឯកសណ្ឋានធំលេខ ១.២.៣ ការងារនិងប្រយុទ្ធដូចទ័ពជើងគោក
- ឯកសណ្ឋានបច្ចេកទេសអយ្យការយោធា ជាឯកសណ្ឋានរួមមាន ២ សំរាប់ ម៉ូតក្រណាត់ ដូចគង អាវុធហត្ថ ពណ៌ត្រែអ៊ី តែគ្មានមួកស៊ីកាសទេ ពាក់បេរ៉េពណ៌ខៀវគ្មានផ្លាកសញ្ញាអាវុធហត្ថឡើយ

ឆ- ឯកសណ្ឋានកងជីវពល :

- ឯកសណ្ឋានកងជីវពលគ្រប់ប្រភេទ រួមមានពីរសំរាប់ គឺ ជាឯកសណ្ឋា សំរាប់ធ្វើការងារ និង ប្រតិបត្តិការមួយសំរាប់ អាវដៃខ្លីមួយសំរាប់ទៀត អាវដៃវែងកាត់ស្រុងវែងដាក់ក្នុងខោ ឯម៉ូត ដ៏ទៃទៀតដូចទ័ពជើងគោក ។
- រូបភាព : អាវក្រណាត់ត្រែអ៊ីពណ៌ខៀវចាស់ ខោក្រណាត់ត្រែអ៊ីពណ៌ត្រែអ៊ី មួកបារមធំហ្សិកគី ពណ៌ខៀវចាស់ ស្បែកជើងសំពត់ពណ៌ត្រែអ៊ី ។

**មាត្រា ២ :** ត្រូវបានរៀបចំឯកសណ្ឋានបច្ចេកទេសទ័ពជំនាញប្រភេទកងនាវាចរណ៍ខេមរភូមិន្ទដូចខាងក្រោមៈ

- ឯកសណ្ឋានបច្ចេកទេសកងនាវាចរណ៍ខេមរភូមិន្ទសំរាប់ក្រុមនាវិកនៅលើកប៉ាល់ ម៉ារីន និង រោង ជាងជួសជុល ពេលធ្វើការងារបច្ចេកទេសដូចជាថែទាំបច្ចេកទេស និងជួសជុល មិនបានពាក់ចេញ ក្រៅកងឯកភាពឡើយ ។
- រូបភាព និង ម៉ូត : ឯកសណ្ឋានក្រណាត់ធធី ពណ៌ទឹកប៊ិច អាវដៃវែង ខោជើងខ្លី និងវែង
- អាវកបើក ថ្នេរឌុប អាវដៃចំពុងមានក្រវ៉ាត់ឡេវ ហោប៉ៅពីរ ដេរយ៉ោតតំរែបរាងចតុកោណកែង ឡេវបង្កប់ ក្រវ៉ាត់ចង្កេះទំហំ ៦ ស.ម ។
- ខោជើងខ្លីលើជង្គង់ ចង្កេះត ជីបភ្លី ហោប៉ៅក្រោយ២ ដេរបង្កប់ តំរែបរាងស្លឹកពោធិ៍ ហោប៉ៅ ចំហៀង ២ បង្កប់តាមថ្នេរខោ ។
- ខោជើងវែងកាត់ដូចខោជើងខ្លី តែខុសត្រង់មួយវែង មួយខ្លី ។
- ខ្សែក្រវ៉ាត់ពណ៌ទឹកប៊ិច ក្បាលខ្សែក្រវ៉ាត់ពណ៌មាសលោហ ។
- មួកហ្សិកគីពណ៌ខៀវ ស្បែកជើងស្បែកពណ៌ខ្មៅ កវែង ស្រោមជើងពណ៌ខ្មៅ ។

**មាត្រា ៣ :** ត្រូវបានរៀបចំឯកសណ្ឋានបច្ចេកទេសទ័ពជំនាញ ប្រភេទកងអាកាសចរណ៍ខេមរភូមិន្ទដូចខាង ក្រោម ÷

- ឯកសណ្ឋានបច្ចេកទេសកងអាកាសចរណ៍ខេមរភូមិន្ទ សំរាប់ក្រុមបច្ចេកទេសយន្តហោះ និង អ្នក ឯកទេសជួសជុលយន្តហោះគ្រប់ប្រភេទ ពេលធ្វើការងារបច្ចេកទេស ដូចជាថែទាំ ធានាបច្ចេក

ទេស និង ជួសជុលមិនបានពាក់ចេញក្រៅអង្គភាពឡើយ ។

- រូបភាព និងម៉ូត ៖ ឯកសណ្ឋានទាំងអស់ដូចឯកសណ្ឋានកងនាវាចរណ៍ខេមរភូមិន្ទ តែគ្មានខោជើងខ្លីទេ ។

- ចំពោះឯកសណ្ឋានអ្នកបើកយន្តហោះគ្រប់ប្រភេទ តាមប្រភេទយន្តហោះ និង តាមលក្ខណៈបច្ចេកទេសជាក់ស្តែង ។

មាត្រា ៤ ៖ ត្រូវបានរៀបចំសញ្ញាប្រភេទទ័ពជំនាញដូចខាងក្រោមនេះ ÷

១- <u>សញ្ញាកងយោធពលខេមរភូមិន្ទ</u> ៖

- រូបភាព ៖ មានរាងមូលផ្នែកខាងលើមានមកុដពណ៌មាសសងខាង មានរំយោលម្ខាង ៣ ផ្ចិតកណ្តាលពណ៌ខៀវ លើផ្ចិតកណ្តាលមានរូបហនុមានកាន់ព្រះខ័ន្ធកំពុងសំដែងរិទ្ធពណ៌ស្វាទុំ នៅរង្វង់ខាងក្រោមពណ៌ក្រហម ឆ្នូតជុំវិញពណ៌មាស នៅលើរង្វង់ផ្ចៃក្រហមសរសេរអក្សរកាត់ « ខ.ភ.ម » ពណ៌ស ។

ខ្នាត ៖

- កំពស់រូបភាព ៦០មម ទទឹង ៤៥មម ។
- កំពស់មកុដ ២៧មម បាត ៣៨ មម ។
- ផ្ចិតខៀវក្នុងកំពស់ ៣២មម ទទឹង ៣០មម ហនុមានកំពស់ ២៤មម ទទឹង ២៤មម ។
- រំយោលសង្ខាងប្រវែង ១៦មម ទីពីរស្មើ ១៤មម ទីបីស្មើ ១២មម ពណ៌មាស ។
- រង្វង់ជើងពានខាងក្រោមមានស្នែងក្របី បណ្តោយប្រវែង ៣៨មម ទទឹងក្រហម ៦មម លឿងព័ទ្ធជុំវិញ ១មម កំពស់អក្សរ ៤មម ។
- សំរាប់ពាក់បន្ថោកពីឡេវហោប៉ៅស្តាំ ធ្វើរាងដូចជាមេដៃ ដាក់លើទង់កងយោធពលខេមរភូមិន្ទតែត្រូវពង្រីកខ្នាតតាមទំហំទង់ ។

២-<u>សញ្ញាអគ្គមេបញ្ជាការ ថ្នាក់ដឹកនាំក្រសួងការពារជាតិ និង ថ្នាក់ដឹកនាំអគ្គសេនាធិការ</u> ៖

- រូបភាព ៖ នៅចំកណ្តាលមានរូបយុថ្កាចញ្ច្រៀរ និង ការលំពែងមានផ្លែបីបញ្ច្រាទៅលើ ខាងក្រោមរូបយុថ្កានៅសង្ខាងមានស្លាបសត្វ មានរាងដូចស្នែងក្របី ។ ផលិតពីលោហធាតុពណ៌មាសកំពស់ ១,៥០ មម ។

- ខ្នាត ៖ កំពស់រូបភាព ៣៦មម ទទឹង ៣៤មម ។

- កំពស់យុថ្កា ២៤មម ចុងផ្លែយុថ្កាពីម្ខាងទៅម្ខាង ២២មម ផ្លែព្រះខ័ន្ធគិតពីចុងយុថ្កាខាងលើទៅ

១១ មម ។ ស្លាបសត្វរាងដូចស្នែងក្របីម្ខាង ៗ មានស្លាបបីជាន់ ជាន់ [illegible] មាន ១ ស្លាប ជាន់ទីពីរមាន ៩ស្លាប ជាន់ទីបីមាន ៧ស្លាប កំពស់ ២៤មម ពីចុងស្លាបខាងលើម្ខាងទៅម្ខាង៣៥មម។

- សំរាប់មេបញ្ជាការកំពូល អគ្គមេបញ្ជាការ ថ្នាក់ដឹកនាំក្រសួងការពារជាតិ និង ថ្នាក់ដឹកនាំអគ្គសេនាធិការ ពាក់នៅលើ កអាវទាំងសង្ខាង រាល់ឯកសណ្ឋានយោធា ។

៣- <u>សញ្ញាកងជើងជើង</u> :

- រូបភាព : មានកាំភ្លើងពីសម័យដើម ២ខ្វែងគ្នា រាងសញ្ញាលេខគុណ កាំភ្លើងខាងស្តាំខ្វែងលើកាំភ្លើងខាងឆ្វេង ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥០មម ។
- ខ្នាត : ប្រវែងកាំភ្លើងនិមួយៗ ៣៥មម ស្មាយកាំភ្លើងនិមួយៗប្រវែង ៤មម ចុងកាំភ្លើង១,៥០មម ចំណុចខ្វែងគ្នាចំពាក់កណ្តាល មុំខាងលើ ១២៥អង្សារ មុំចំហៀង ៥៥អង្សារ ។
- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានថ្មើរជើង ពាក់នៅលើកអាវទាំងសង្ខាង រាល់ឯកសណ្ឋានយោធា ។

៤- <u>សញ្ញាកងនាវាចរណ៍ខេមរភូមិន្ទ</u> :

- រូបភាព : មានរូបសញ្ញាយុថ្កាពីរខ្វែងគ្នាចំណុចប្រសព្វជាមុំកែងនៅពាក់កណ្តាលរំលេចដោយខ្សែពួរពីរព័ទ្ធជុំវិញយុថ្កានិមួយៗ ផលិតពីលោហធាតុពណ៌មាស មានកំរាស់ ១,៥មម ។
- ខ្នាត : ទំហំរូបភាពសញ្ញាជាការ៉េ ដែលមានជ្រុងប្រវែង ៣០មម ។
- ប្រវែងយុថ្កានិមួយៗ ៣៦មម ។
- ទំហំដងយុថ្កាប្រវែងទទឹង ២មម ។
- រង្វង់កងដងយុថ្កាដែលមានបន្ទាត់ផ្ចិតខាងក្រៅ ៤មម និង បន្ទាត់ផ្ចិតខាងក្នុង ២មម ។
- ទំហំខ្សែ ១មម ។
- ប្រវែងដែកខ្វែងយុថ្កា ១០មម ទំហំ ១,៥មម ឃ្លាតពីកងយុថ្កា ៣មម ។
- ចុងផ្លែយុថ្កាម្ខាងទៅម្ខាងប្រវែង ១៦មម ។
- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហាន នាវាចរណ៍ខេមរភូមិន្ទពាក់លើកអាវទាំងសងខាងរាល់ឯកសណ្ឋានយោធា ។

៥- <u>សញ្ញាកងនាវាចរណ៍ខេមរភូមិន្ទ សំរាប់ដាក់លើហ្លួងសក្តិ</u> :

- រូបភាព : រូបយុថ្កាពីរប្រសព្វជាមុំកែងនៅចំកណ្តាលដងដែលមានព័ទ្ធជុំវិញដោយខ្សែ ។ ហើយ

មានម្កុដនៅលើយុថ្កាទាំងពីរ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

- ខ្នាត ៖ កំពស់រូបភាព ៣៤មម ទទឹង ២០មម ។
- ម្កុដមានបាតទទឹងក្រោម ១៦មម កំពស់ម្កុដ ២៨មម ។
- យុថ្កានិមួយៗប្រវែង ២៧មម ទទឹង ១៣មម នៅចុងជងយុថ្កាមានរង្វង់មូលមានបន្ទាត់ផ្ចិតខាងក្រៅ ០៣មម ខាងក្នុង ១,៥មម ។
- នៅលើជងយុថ្កាមានដែកកាត់ទទឹងប្រវែង ០៧មម ទំហំ ០១មម ឃ្លាតពីរង្វង់ប្រវែង ០៥មម ។
- ទំហំខ្សែព្យួរយុថ្កា ០១មម ។
- ផ្លែយុថ្កានិមួយៗ ពីចុងម្ខាងទៅចុងម្ខាង ១៤មម ។
- សំរាប់ដាក់នៅលើហ្លួងសក្តិគ្រប់ប្រភេទរបស់កងនាវាចរណ៍ខេមរភូមិន្ទលើកលែងតែសក្តិប្រយុទ្ធ

៦- សញ្ញាកងអាកាសចរណ៍ខេមរភូមិន្ទ ដាក់លើឈោប៉ៅស្មា ៖

- រូបភាព ៖ រូបស្លាបសត្វ នៅពីលើរូបស្លាបសត្វចំពាក់កណ្តាលមានរូបម្កុដ ធ្វើពីលោហធាតុពណ៌មាស កំរាស់ ១មម ។
- ខ្នាត ៖ រូបភាពកំពស់ ៣២មម ទទឹង ៥៥មម ។
- ម្កុដមានបាតក្រោមប្រវែង ១៤មម កំពស់ គិតពីរូបស្លែងរបស់ម្កុដដល់ចុងខាងលើមានប្រវែង ២៥ មម ។
- ស្លាបសត្វម្ខាងៗមានពីរជាន់ ជាន់ទីមួយមានស្លាប ៩ ទីពីរមានស្លាប ៧ ។
- សំរាប់នាយទាហាន នាយទាហានរង អាកាសចរណ៍ខេមរភូមិន្ទ ពាក់លើឈោប៉ៅស្មា រាល់ឯកសណ្ឋានយោធា ។

៧- សញ្ញាអាកាសចរណ៍ខេមរភូមិន្ទដាក់លើហ្លួងសក្តិ ៖

- រូបភាព ៖ មានរូបស្លាបសត្វ និងរូបម្កុដដាក់ពីលើចំកណ្តាល ផលិតពីលោហធាតុពណ៌មាស កំរាស់ ១មម ។
- ខ្នាត ៖ រូបភាពមានកំពស់ ២៥មម ទទឹង ៣៥មម ។
- រូបម្កុដមានបាតក្រោមប្រវែង ១០មម កំពស់ពីរូបស្លែងម្កុដទៅលើប្រវែង ២១មម ។
- ស្លាបសត្វនិមួយៗមានមួយជាន់ មានស្លាបចំនួន ៤ ។
- រូបភាពនេះសំរាប់ដាក់លើហ្លួងសក្តិគ្រប់ប្រភេទរបស់កងនាវាចរណ៍ខេមរភូមិន្ទ លើកលែងតែ

សក្តិប្រយុទ្ធ ។

៨- <u>សញ្ញាអាកាសចរណ៍ខេមរភូមិន្ទពាក់លើអាវ</u> :

- រូបភាព : < ដូចរូបអាកាសចរណ៍ខាងលើ > ផលិតពីលោហធាតុពណ៌មាស កំរាស់ ១មម ។

- ខ្នាត : រូបភាពមានកំពស់ ៣០មម ទទឹង ៣៥មម ។

- ម្កុដមានបាតក្រោមប្រវែង ៩មម កំពស់ ២១មម ។

- ស្លាបសត្វនីមួយៗ មានមួយជាន់ មានស្លាបចំនួន ៥ ។

- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានអាកាសចរណ៍ខេមរភូមិន្ទ ពាក់លើកអាវ រាល់ឯកសណ្ឋានយោធា ។

៩- <u>សញ្ញាអាកាសយានិកសំគាល់សញ្ញាប័ត្រហោះហើរ</u>

៩-១ <u>អ្នកបើកបរយន្តហោះ</u> :

- រូបភាព : មានរូបសត្វហង្សកំពស់ត្រដាងស្លាបឈរក្នុងរង្វង់មូល មានក្បាច់ផ្កាភ្ញីពីសម័យអង្គរ ចំនួនបីជាន់ ខាងក្រោមមានចងខ្សែបូ រូបភាពពណ៌មាស ។

- ខ្នាត : កំពស់សត្វហង្សប្រវែង ២៨មម ទទឹងពីចុងស្លាបម្ខាងទៅម្ខាងប្រវែង ៧០មម ហើយ រូបហង្សឈរត្រដាងស្លាបធម្មតា ។

- រង្វង់ក្បាច់ផ្កាភ្ញី ខាងក្នុងមានបន្ទាត់ផ្ចិតប្រវែង ៣០មម ខាងក្រៅមានបន្ទាត់ផ្ចិត ៤០មម ។

- រូបភាពនេះសំរាប់ដាក់លើសញ្ញាប័ត្ររបស់អាកាសយានិក អ្នកបើកបរយន្តហោះ ។

៩-២ <u>សញ្ញាសំគាល់សញ្ញាប័ត្រហោះហើរយន្តការី</u>

- រូបភាព : ខ្នាត និង ពណ៌ដូចរូបភាពទី១ តែខុសគ្នានៅជើងសត្វហង្សមានរូបសញ្ញាគ្រឿងចក្រ មានបន្ទាត់ផ្ចិតខាងក្រៅប្រវែង ៨មម ខាងក្នុង ៣មម ។

- សំរាប់ដាក់លើសញ្ញាប័ត្រហោះហើររបស់យន្តការី ។

៩-៣ <u>សញ្ញាសំគាល់សញ្ញាប័ត្រហោះហើរបុគ្គលិកបង្ហាញផ្លូវ</u> :

- រូបភាព ខ្នាត និង ពណ៌ដូចខាងលើ តែខុសគ្នានៅលើជើងសត្វហង្សមានរូបសញ្ញាផែនដី មាន បន្ទាត់ផ្ចិត ៨មម ។

- សំរាប់ដាក់លើសញ្ញាប័ត្រហោះហើររបស់បុគ្គលិកបង្ហាញផ្លូវ ។

៩-៤ <u>សញ្ញាសំគាល់សញ្ញាប័ត្រហោះហើរបុគ្គលិកវិទ្យុទាក់ទង</u>

- រូបភាព ខ្នាត និង ពណ៌ដូចរូបភាពខាងលើ តែខុសត្រង់នៅជើងសត្វហង្សមានរូបសញ្ញាផែនដី និងមានសញ្ញាលេខធាតុអាកាសនៅចំកណ្តាល ។ បន្ទាត់ផ្ចិតរង្វង់រូបផែនដីប្រវែង ៨មម ។
- សំរាប់ដាក់លើសញ្ញាប័ត្រហោះហើររបស់បុគ្គលិកវិទ្យុទាក់ទងនិងបង្ហាញផ្លូវ ។

១០- <u>សញ្ញាកងឯកភាពដឹកជញ្ជូន</u> :

- រូបភាព : មានរូបចង្កូតកប៉ាល់ ចង្កូតរថយន្ត ត្រួតពីលើបង្កើតបានជាសញ្ញាគ្រឿងចក្រ នៅចំកណ្តាលមានរូបស្លាបសត្វផលិតពីលោហធាតុពណ៌មាស ស្លាបសត្វពណ៌ប្រាក់ កំរាស់ ១,៥មម ។
- ខ្នាត : រង្វង់បន្ទាត់ផ្ចិតខាងក្រៅ ៣៥មម ខាងក្នុង ២៦មម កាំបណ្តុះជុំវិញរង្វង់ចំនួន ១៦ បណ្តុះចេញពីរង្វង់ខាងក្រៅ ២មម ប្រវែងឃ្លាតពីមួយទៅមួយ ២មម ។ កាំមេស់ចង្កូតចំនួន ៨ ចង្អុល ៨ ទិស នៅកណ្តាលស្លាបសត្វប្រវែងបណ្តោយ ១៦មម កំពស់ ១០មម ស្លាបមាន ២ ជាន់ មួយជាន់ៗ មាន ៦ ស្លាប ។
- សំរាប់នាយទាហាន នាយទាហានរង និងពលទាហានកងឯកភាពដឹកជញ្ជូនគ្រប់ប្រភេទពាក់លើកអាវទាំងសង្ខាងរាល់ឯកសណ្ឋានយោធា ។

១១- <u>សញ្ញាកងចលនូបត្ថម្ភនិងសំភារៈ</u> :

- រូបភាព : មានរូបក្អមនៅខាងលើមានអណ្តាតភ្លើងនៅលើក្អមមានតួរង្វង់រាងពងក្រពើ ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១,៥មម ។
- ខ្នាត : ក្អមមានរាងជារង្វង់បន្ទាត់ផ្ចិត ១៥មម មាត់ក្អម ៨មម កំពស់កក្អម ១មម អណ្តាតភ្លើងនៅលើមាន ៤ កំពស់អណ្តាតទីមួយ ១៨ មម ទីពីរ ១៦ មម ទីបី ១៤ មម ទីបួន ១២ មម អណ្តាតភ្លើងនិមួយៗប្រវែងទទឹង ២មម ស្រួចចុងរាងជាអណ្តាតភ្លើង ។
- សំរាប់នាយទាហាន នាយទាហានរង និងពលទាហានកងឯកភាពភស្តុភារ ពាក់លើកអាវទាំងសង្ខាងរាល់ឯកសណ្ឋានយោធា ។

១២- <u>សញ្ញាកងឯកភាពសុខាភិបាល</u>

- រូបភាព : មានសញ្ញាលេខបូកត្រង់ទៅលើមានពស់រុំនៅពីលើ ធ្វើពីលោហធាតុ សញ្ញាលេខបូកពណ៌ក្រហម ពស់ពណ៌ប្រាក់ ។
- ខ្នាត : សញ្ញាលេខបូកនិមួយៗប្រវែង ៣៤មម ទទឹង ១០មម នៅសញ្ញាលេខបូកត្រង់ទៅលើចំកណ្តាលមានឆ្នូតបណ្តោយប្រវែង ៦មម សំរាប់ពស់រុំ ពស់រុំមិនជាន់ក្បាលពស់ផុតពីខាងលើ កន្ទុយ

ពស់ចុះមកក្រោម ២មម ទទឹងពស់ ២មម ។

- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានកងឯកភាពសុខាភិបាលកងយោធពលខេមរភូមិន្ទ ពាក់លើកអាវទាំងសង្ខាងរាល់ឯកសណ្ឋានយោធា ។

១៣- សញ្ញាកងឯកភាពភូមិសាស្ត្រយោធា :

- រូបភាព : មានរូបផែនទីព្រះរាជាណាចក្រកម្ពុជាពណ៌មាស ក្នុងនោះមានទន្លេសាប ទន្លេមេគង្គ នៅលើផែនទីមានរូបកុំប៉ាបញ្ឈរពណ៌ប្រាក់ ផលិតពីលោហធាតុ ។

- ខ្នាត : ទំហំផែនទីទទឹងប្រវែង ៣០មម កំពស់ ២៤មម កំពស់កុំប៉ា ៣០មម មុំរបស់ចុងកុំប៉ាបើកចេញពីគ្នា ៥០អង្សា ចុងកុំប៉ាមួយទៅមួយ ២០មម ផល់កុំប៉ាលើហៀនហួសផែនទី ៤មម ចុងខាងក្រោមហៀនហួសផែនទី ២មម ។

- សំរាប់នាយទាហាន នាយទាហានរង និងពលទាហានកងឯកភាពភូមិសាស្ត្រយោធា ពាក់លើកអាវទាំងសង្ខាងរាល់ឯកសណ្ឋានយោធា ។

១៤- សញ្ញាកងកាំភ្លើងធំនិងការពារដែនអាកាស :

- រូបភាព : មានកាំជ្រួចមួយបញ្ឈរត្រង់ទៅលើ ហើយមានកាណុងកាំភ្លើងធំពីសម័យដើមពីរខ្វែងគ្នាដាក់ពីលើរូបកាំជ្រួច ។ កាណុងខាងឆ្វេងខ្វែងលើខាងស្តាំ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

- ខ្នាត : កំពស់កាំជ្រួច ៣៤មម កាណុងកាំភ្លើងធំនីមួយៗប្រវែង ៣៤មម មុំកាណុងកាំភ្លើងធំខ្វែងគ្នាមានទំហំមុំខាងលើនិងខាងក្រោម ១១០ អង្សា មុំចំហៀង ៧០ អង្សា ។

- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានកងកាំភ្លើងធំ កាំជ្រួច និង កងការពារដែនអាកាស ពាក់នៅលើកអាវទាំងសង្ខាងរាល់ឯកសណ្ឋានយោធា ។

១៥- សញ្ញាកងរថក្រោះ រថពាសដែក :

- រូបភាព : រូបដាវពីរខ្វែងគ្នា នៅចំកណ្តាលមានរូបរថក្រោះ មើលពីមុខនិងក្រចកសេះផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

- ខ្នាត : ដាវនីមួយៗប្រវែង ៤២មម < ក្នុងនោះដងដាវ ៨មម > ទទឹងរថក្រោះ ២០មម កំពស់ទាំងកាណុង ១៤មម កំពស់ក្រចកសេះ ១៧មម ចុងក្រចកសេះខាងលើពីមួយ ទៅមួយ ៩មម លើក្រចកសេះមានស្នាមបោះដែកគោលចំនួន ៥ កន្លែង ។

- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានរថក្រោះ រថពាសដែកពាក់លើកអាវទាំងសង្ខាង រាល់ឯកសណ្ឋានយោធា ។

១៦- សញ្ញាកងឯកភាពបញ្ជូនសារ :

- រូបភាព : រូបកងចក្រមានស្លាបខាងក្រៅចំនួន ១៦ នៅលើរូបកងចក្រមានរូបសញ្ញាលេកធាតុអាកាសមុខឡើងទៅលើចុងងាកមកស្តាំ ២៥ អង្សា ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម

- ខ្នាត : បន្ទាត់ផ្ចិតកងចក្រខាងក្រៅ ៣៥មម រង្វង់ខាងក្នុងទីមួយប្រវែង ២០មម និង ទី២ ប្រវែង ១៥មម សញ្ញាលេកធាតុអាកាស បណ្តោយប្រវែង ៣៦មម ទទឹងតួសញ្ញា ៨មម ។

- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហាន បញ្ជូនសារពាក់លើកអាវទាំងសង្ខាង រាល់ឯកសណ្ឋានយោធា ។

១៧- សញ្ញាកងវិស្វកម្ម :

- រូបភាព : មានរូបវិមានឯករាជ្យបញ្ឈរខាងក្រោមមានកាំជណ្តើរបីថ្នាក់ ប្រាសាទខាងលើមានថ្នាក់ ៧ ជាន់ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

- ខ្នាត : កំពស់ ៣២មម បាតក្រោម ១៦មម តួកណ្តាល ១២មម ថ្នាក់ក្បាច់ទី១ បន្ទាប់ពីតួកណ្តាល ១៤មម ។

- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានវិស្វកម្មពាក់នៅលើកអាវទាំងសង្ខាង រាល់ឯកសណ្ឋានយោធា ។

១៨- សញ្ញាកងឯកភាពសាលា :

- រូបភាព : មានរូបព្រះខ័ន្តខ្វែងជាមួយស្លាបសត្វមួយ នៅកណ្តាលមានសៀវភៅមួយបើក ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

- ខ្នាត : ព្រះខ័ន្តប្រវែង ៣៥មម ស្លាបសត្វមួយ ៣៥មម កំពស់សៀវភៅ ១០មម បណ្តោយ១៤មម ផ្ចិតកណ្តាលសៀវភៅ ១២មម ។

- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហាន កងឯកភាពសាលាគ្រប់ថ្នាក់ពាក់លើកអាវទាំងសង្ខាង រាល់ឯកសណ្ឋានយោធា ។

១៩- សញ្ញាកងឯកភាពតុលាការយោធា :

- រូបភាព : រូបក្បាច់ចម្លាក់អង្គរព័ទ្ធជុំវិញរាងស្លែងគ្រុបីចំកណ្តាលជើងពានជញ្ជីងនិងសន្លឹកសៀវ

គ្រាប់ផ្ទាប់ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

- ខ្នាត : បន្ទាត់ផ្ចិតរង្វង់ក្បាច់ចម្លាក់អង្កត់ខាងក្រៅ ៣៥មម ខាងក្នុង ២៧មម ជើងពាន និង ដង ជញ្ជីងប្រវែង ២៤មម ដងឆ្កាងជញ្ជីង ១៣មម សន្លឹកសៀវភៅច្បាប់រៀបកាត់ក្រោងពីលើដងជញ្ជីង ត្រាប៉ក់កន្លែងចាប់ជញ្ជីងកំពស់ ៥មម ជញ្ជីងបន្ទោតចុះ ៦មម ។

- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានតុលាការយោធា ប់ផ្ទាក់ពាក់លើកអាវទាំង សង្ខាងរាល់ឯកសណ្ឋានយោធា ។

២០- សញ្ញាកងឯកភាពអយ្យការយោធា :

- រូបភាព : មានរូបជើងពានចំនួនបីថ្នាក់ទ្រជញ្ជីងផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម

- ខ្នាត : កំពស់រូបភាព ៣០មម បាតជើងពានខាងក្រោម ១៦មម បាតជើងពានទី២ប្រវែង ១០មម មាត់ជើងពានទី ២ប្រវែង ២០មម បាតជើងពានទី ៣ប្រវែង ១១មម មាត់លើប្រវែង ១៥មម បង្គោលជញ្ជីង ៥មម ដងជញ្ជីងរាងកោងចុងមានក្បាច់ប្រវែង ១៧មម ជញ្ជីងបន្ទោតចុះ ៦មម កំពស់ជញ្ជីងទី១ និងទី២ ប្រវែង ១៥មម ជើងពានទី៣ ៦មម ។

- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានអយ្យការយោធាពាក់លើកអាវទាំងសង្ខាង រាល់ឯកសណ្ឋានយោធា ។

២១- សញ្ញាត្រៃទ័ពនិងសិល្បៈកងយោធពលខេមរភូមិន្ទ :

- រូបភាព : មានរូបអក្សរភ្លេងពីសម័យដើម ញូផលិតពីលោហធាតុពណ៌មាស ។

- ខ្នាត : កំពស់រូបភាព ៣៥មម បាតក្រោម ១២មម ទទឹងរូបភាពកណ្តាល ២៧មម តំនូសកាត់ខាង លើ ២២មម កំរាស់ ១,៥មម ។

- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានត្រៃទ័ព និងសិល្បៈកងយោធពលខេមរភូមិន្ទ ពាក់លើកអាវទាំងសង្ខាងរាល់ឯកសណ្ឋានយោធា ។

- ចំពោះសញ្ញាទ័ពជំនាញនិងប្រភេទដែលគ្មាន កំណត់ខាងលើត្រូវពាក់សញ្ញាកងទ័ពថ្មើរជើង ។

២២- សញ្ញាកងឯកភាពត្រៃយោង :

- សញ្ញាកងឯកភាពត្រៃយោងមាន ៣ ប្រភេទ ÷

- ទី១ រូបភាព : មានរូបប្រាសាទអង្គរវត្តកំពូលបី នៅចំកណ្តាលស្លាបសត្វនៅពីលើនៅចំកណ្តាល មានរូបព្រះខ័ន្ធមុខចុះក្រោម នៅកណ្តាលព្រះខ័ន្ធមានរូបតួអក្សរ " ន " ខាងក្រោមកណ្តាលមាន

បន្ទោកចុងស្រួចរាងត្រីកោណ ។ ធ្វើពីលោហធាតុប្រាសាទអង្គរពណ៌មាស ព្រះខ័ន្ធ និងស្លាបសត្វពណ៌ប្រាក់ រំយោលចុងស្រួចចំកណ្ដាលចុះក្រោមពណ៌ក្រហមអក្សរ " ឆ " ពណ៌ខៀវកំរាស់ ១,៥មម ។

- ខ្នាត : កំពស់រូបភាព ៣៧មម ទទឹង ៧០មម ។
- បាតប្រាសាទអង្គរវត្តប្រវែង ៣២មម កំពស់ប្រាសាទ១៥មម ព្រះខ័ន្ធប្រវែង២២មម កំពស់អក្សរ " ឆ " ១០មម កំពស់ស្លាបសត្វ ១៥មម រំយោលចុះក្រោម ១៤មម ស្លាបសត្វមានពីរជាន់ ជាន់ទីមួយ ១១ស្លាប ជាន់ទីពីរមាន ១០ ស្លាប ។
- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានកងឆ័ត្រយោង ពាក់នៅលើបេរ៉េ និងលើហោរជៅខាងស្ដាំរាល់ឯកសណ្ឋានយោធា និង ដាក់លើសញ្ញាប័ត្រកងឆ័ត្រយោង ។
- ទី២ រូបភាព : មានឆ័ត្រយោងស្លាបសត្វ និង ខាងក្រោមក្បាច់ផ្កាភ្ញីទ្រពីខាងក្រោម ផលិតពីលោហធាតុ ឆ័ត្រយោងនិងស្លាបសត្វពណ៌ទឹកប្រាក់ ផ្កាភ្ញីពណ៌មាស កំរាស់ ១,៥មម ។
- ខ្នាត : កំពស់រូបភាព ៤៥មម ទទឹង ៨២មម ។
- កំពស់ឆ័ត្រយោង ៣៥មម ខ្សែឆ័ត្រ ២១មម ឆ័ត្រប្រវែង ១៩មម ទទឹងឆ័ត្រខាងក្រោមចុងឆ័ត្រ និង ខ្សែចន្លោះគល់ស្លាបខាងលើទាំងពីរប្រវែង ៣០មម គល់ស្លាបខាងលើទៅចុងស្លាបម្ខាង ៗ ប្រវែង ២៥មម ក្បាច់ផ្កាភ្ញីខាងក្រោមរង្វង់ស្នែងក្របី ខាងក្រោមផ្កាឈូកមានបន្ទាត់ផ្ចិត ១២មម ផ្កាភ្ញីសងខាងប្រវែង ២២មម ។
- សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានកងឆ័ត្រយោងដែលបានលោតឆ័ត្រយោងលើសពី ១០ដងឡើងទៅ សំរាប់ពាក់លើបេរ៉េ និង លើហោរជៅខាងស្ដាំរាល់ឯកសណ្ឋានយោធា និង ដាក់លើសញ្ញាប័ត្រកងឆ័ត្រយោង ។
- ទី៣ រូបភាព : រូបភាពនិងខ្នាតពណ៌មានដូចរូបទីពីរ តែបន្ថែមនៅចំកណ្ដាលចំណុចគល់ស្លាបខាងក្រោមមានគងចិញ្ចូលគ្នាខាងលើពណ៌ក្រហម ខាងឆ្វេងពណ៌លឿង ខាងស្ដាំពណ៌ខៀវ រៀបរាងមុំចង្ក្រាន បន្ទាត់ផ្ចិតខាងក្រៅ ៨មម ខាងក្នុង ៦មម ។
- សំរាប់នាយទាហាន នាយទាហានរងជាគ្រូបង្ហាត់ឆ័ត្រយោងពាក់នៅលើបេរ៉េ និងលើហោរជៅខាងស្ដាំរាល់ឯកសណ្ឋានយោធា ដាក់លើសញ្ញាប័ត្រគ្រូឆ័ត្រយោង ។

**មាត្រា ៥** : ទង់កងទ័ពជាតិកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម ៖

១- ទង់កងយោធពលខេមរភូមិន្ទ :

- យកតួទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទកំពូល៣ បណ្តោយ១,៩៥ម ទទឹង១,៤៦២៥ម ដងទង់ ២,៨៥ម នៅផ្នែកខាងលើជ្រុងខាងដើម មានរូបហនុមានកាន់ព្រះខ័ន្ធពណ៌មាស កំពស់រូបហនុមាន ២៥សម ទទឹង ២២សម នៅក្រោមប្រាសាទសរសេរអក្សរពណ៌មាស " កងយោធពលខេមរភូមិន្ទ " កំពស់អក្សរ ១៥សម នៅក្បាលដងទង់ស្រួចខាងលើឆ្លាក់រូបម្កុដមានព្រះខ័ន្ធទ្រ ពណ៌មាស ធ្វើពីលោហធាតុ នៅកក្បាលដងទង់មានរំយោល ២ ពណ៌មាសមួយប្រវែង ១ម មួយទៀតប្រវែង ១,២៥ម ។

២- ទង់អគ្គសេនាធិការ កងយោធពលខេមរភូមិន្ទ :

- យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទអង្គរវត្តកំពូល ៣ មានបណ្តោយ ១,៩៥ម ទទឹង ១,៤៦២៥ម ដងទង់ ២,៨៥ម ។ នៅជ្រុងខាងលើផ្នែកខាងដើមទង់មានរូបសញ្ញាអគ្គសេនាធិការ មានទំហំកំពស់រូបភាព ២៥សម ទទឹង ២២សម ។ នៅខាងក្រោមប្រាសាទលើផ្ទៃពណ៌ខៀវ មានសរសេរអក្សរពណ៌មាស " អគ្គសេនាធិការ កងយោធពលខេមរភូមិន្ទ " កំពស់អក្សរ ១៥សម ។
- នៅក្បាលដងទង់ស្រួច ខាងលើឆ្លាក់រូបម្កុដមានព្រះខ័ន្ធទ្រ ធ្វើពីលោហធាតុពណ៌មាស នៅក្បាលដងទង់មានរំយោល ២ ពណ៌មាសមួយប្រវែង ១ម មួយទៀតប្រវែង ១,២៥ម ។ ដោយឡែកអាកាសចរូបម្កុដមានស្លាបសត្វទ្រ និងនាវាចររូបម្កុដមានរូបយុថ្កាទ្រពីក្រោម ។

៣- ទង់ជ័យយោធភូមិភាគ ប្រភេទទ័ព និង ថ្នាក់ប្រហាក់ប្រហែល :

- យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទអង្គរវត្តកំពូល ៣ មានបណ្តោយ ១,៨០ម ទទឹង ១,៣៥ម ដងទង់ ២,៨០ម នៅជ្រុងខាងដើមផ្នែកខាងលើមានរូបសញ្ញាទ័ពជំនាញ កំពស់ ២៥សម ទទឹង ២២សម ពណ៌មាស នៅខាងក្រោមប្រាសាទសរសេរអក្សរពណ៌មាសឈ្មោះកងឯកភាពនិមួយៗ កំពស់អក្សរ ១៥សម ។ នៅក្បាលដងទង់ស្រួចខាងលើឆ្លាក់រូបម្កុដមានព្រះខ័ន្ធទ្រ ធ្វើពីលោហធាតុពណ៌មាស នៅកក្បាលដងទង់មានរំយោល ២ពណ៌ មួយប្រវែង ១ម មួយទៀតប្រវែង ១,២៥ម ។ ដោយឡែកអាកាចររូបម្កុដមានស្លាបសត្វទ្រ និងនាវាចររូបម្កុដមានយុថ្កាទ្រពីក្រោម ។

៤- ទង់ជ័យថ្នាក់កងពលធំ តំបន់ប្រតិបត្តិការសឹក និង ថ្នាក់ប្រហាក់ប្រហែល :

- យកទង់ជាតិព្រះរាជាណាចក្រកម្ពុជាប្រាសាទអង្គរវត្តកំពូល៣ បណ្តោយ ១,៧០ម ទទឹង១,២៧៥ម ដងទង់ ២,៥៥សម នៅជ្រុងខាងដើមផ្នែកខាងលើមានរូបទ័ពជំនាញកំពស់ ២៥សម ទទឹង ២២សម

ពណ៌មាស ខាងក្រោមប្រាសាទសរសេរអក្សរពណ៌មាស ឈ្មោះកងឯកភាពនិមួយៗ កំពស់អក្សរ ១៥សម ។ នៅក្បាលដងទង់ស្រួចខាងលើឆ្លាក់រូបម្កុដមានព្រះខ័ន្ធទ្រ ធ្វើពីលោហធាតុពណ៌មាស នៅក្បាលដងទង់មានរំយោល ២ ពណ៌មាស មួយប្រវែង ១ម មួយទៀតប្រវែង ១,២៥ម ។ ដោយឡែកអាកាសចររូបម្កុដមានស្លាបសត្វទ្រ និងនាវាចររូបម្កុដមានយុថ្កាទ្រពីក្រោម ។

៥- ទង់ជ័យថ្នាក់កងពលតូច វរសេនាធំ និង ថ្នាក់ប្រហាក់ប្រហែល :

- យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទអង្គរវត្តកំពូល ៣ មានបណ្តោយ ១,៦០ម ទទឹង ១,២០ម ដងទង់ ២,៤០ម ។ នៅជ្រុងខាងដើមផ្នែកខាងលើមានរូបសញ្ញាទ័ពជំនាញពណ៌មាស មានកំពស់ដូចខាងលើ ខាងក្រោមប្រាសាទអង្គរវត្តសរសេរអក្សរពណ៌មាស ឈ្មោះកងឯកភាពនិមួយៗ " កំពស់អក្សរ ១៥សម "។ នៅក្បាលដងទង់ស្រួចខាងលើឆ្លាក់រូបម្កុដ មានព្រះខ័ន្ធទ្រ ធ្វើពីលោហធាតុពណ៌មាស នៅក្បាលដងទង់មានរំយោល ២ ពណ៌មាស មួយប្រវែង ១ម មួយទៀតប្រវែង ១,២៥ម ។ ដោយឡែកអាកាចររូបម្កុដមានស្លាបសត្វទ្រ និងនាវាចររូបម្កុដ មានរូបយុថ្កាទ្រពីក្រោម ។

**មាត្រា ៦ :** ចំពោះផ្លាកសំគាល់គ្រប់កងឯកភាពនៃកងយោធពលខេមរភូមិន្ទ អគ្គសេនាធិការជាអ្នកកំណត់ ។

**មាត្រា ៧** រាល់ឯកសណ្ឋានបច្ចេកទេសទ័ពជំនាញ សញ្ញាសំគាល់ប្រភេទទ័ព និង ទង់ជ័យទ័ព ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង នាយអគ្គសេនាធិការ ត្រូវអនុវត្តន៍អនុក្រឹត្យនេះ ។

**មាត្រា ៩ :** អនុក្រឹត្យនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃឡាយព្រះហស្ថ និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

## ឧបសម្ព័ន្ធទី ១

## រូបភាពសញ្ញាប្រភេទផ្សេងៗរបស់កងយោធពលខេមរភូមិន្ទ

**១ : សញ្ញាកងយោធពលខេមរភូមិន្ទ**




រូបភាព : មានរាងមូលផ្នែកខាងលើ មានម្កុដពណ៌មាសសងខាង មានរំយោលម្ខាងបីផ្នែកកណ្ដាលពណ៌ខៀវលើផ្ទៃកណ្ដាលមានរូបហនុមានកាន់ព្រះខ័ន្តកំពុងសំដែងឫទ្ធិ ពណ៌ស្វាទុំ នៅវិណ្ឌខាងក្រោមពណ៌ក្រហម ឆ្នូតជុំវិញពណ៌មាស នៅលើវិណ្ឌផ្ទៃក្រហមសរសេរអក្សរកាត់ "ខ.ភ.ម." ពណ៌ស។

ខ្នាត :-កំពស់រូបភាព ៦០មម ទទឹង ៤៥មម ។

-កំពស់ម្កុដ ២៧មម បាត ៣៨មម ។

-ផ្ទៃខៀវខាងក្នុងកំពស់៣២មម ទទឹង ៣០មម ហនុមានកំពស់ ២៤មម ទទឹង ២៤មម ។

-រំយោលសង្ខាងប្រវែង ១៦មម ទីពីរ ១៤មម ទីបី ១២មម ពណ៌មាស ។

-វិណ្ឌជើងពានខាងក្រោមរាងស្នែងក្របីបណ្ដោយប្រវែង៣៨មម ទទឹងក្រហម៦មម ជៀងព័ទ្ធជុំវិញ ១មម ។

**២ : សញ្ញាអគ្គមេបញ្ជាការ ថ្នាក់ដឹកនាំក្រសួងនិងអគ្គសេនាធិការ**



រូបភាព :នៅចំកណ្ដាលមានរូបយុគ្គ័ាបញ្ឈរនិងមានលំពែងមានផ្លែបញ្ឈរទៅលើខាងក្រោមរូបយុគ្គ័ានៅសង្ខាងមានរូបស្លាបរាងដូចស្នែងក្របី ។ ផលិតពីលោហធាតុពណ៌មាសកំរាស់១,៥មម

ខ្នាត :-កំពស់រូបភាព ៣៦មម ទទឹង ៣៥មម ។

-កំពស់យុគ្គ័ា២៥មម ចុងផ្លែយុគ្គ័ាម្ខាងទៅម្ខាង២២មមផ្លែច្បូកចិតពីដងយុគ្គ័ាខាងលើទៅ ១១មម ស្លាបសត្វរាងដូចស្នែងក្របី ម្ខាងៗ មានស្លាបបីជាន់ ជាន់ទីមួយមាន ១១ ស្លាប ជាន់ទីពីរមាន ៩ស្លាប ជាន់ទីបីមាន ៧ស្លាប កំពស់ ២៤មម ពីចុងស្លាបខាងលើម្ខាងៗ ៣៥មម ។

៣ : សញ្ញាថ្មើរជើង ទ័ពជើងគោក



រូបភាព : មានរូបកាំភ្លើងពីសម័យដើម ២ខ្វែងគ្នាពាងសញ្ញាលេខគុណ កាំភ្លើងខាងស្តាំខ្វែងលើកាំភ្លើងខាងឆ្វេងផលិតពីលោហធាតុពណ៌មាស គំរាស់ ១,៥មម ។

ខ្នាត : ប្រវែងកាំភ្លើងនិមួយៗ ៣៥មម ស្មាយកាំភ្លើងនិមួយៗប្រវែង ៤មម ចុងកាំភ្លើងប្រវែង ១,៥មម ចំណុចខ្វែងគ្នាចំពាក់កណ្តាល មុំខាងលើ២៥អង្សា មុំចំហៀង ៥៥ អង្សា ។

## គ្រឿងសញ្ញាកងនាវាចរ

៤ : សញ្ញាកងនាវាចរណ៍ខេមរភូមិន្ទ



រូបភាព : រូបសញ្ញាយុថ្កាពីរខ្វែងគ្នា ប្រសព្វគ្នាជាមុមកែងនៅចំពាក់កណ្តាលរំលេចដោយខ្សែពួរពីរ ព័ទ្ធជុំវិញយុថ្កានិមួយៗ ជាពណ៌ទឹកមាស ។

ខ្នាត : -ទំហំរូបសញ្ញាជាការ៉េ ដែលមានជ្រុងប្រវែង ៣០មម

-យុថ្កានិមួយៗប្រវែង ៣៥មម

-ទំហំដងយុថ្កានិមួយៗប្រវែង ២មម

-ទំហំកន្ទុយយុថ្កាជារង្វង់មូលដែលមានបន្ទាត់ផ្ចិតខាងក្រៅ ៤មម និងបន្ទាត់ផ្ចិតក្នុង ២មម

-ទំហំខ្សែ ១មម

-ដៃកាត់ទទឹងយុថ្កាទំហំ ១,៥មម ឃ្លាតពីក្បាលរង្វង់មូលនៃកន្ទុយយុថ្កាប្រវែង ៥មម ។

៥ : សញ្ញាកងនាវាចរណ៍ខេមរភូមិន្ទ
ដាក់លើហ្លួងសក្តិ



រូបភាព :-យុថ្កា ២ ប្រសព្វគ្នាជាមុមកែងនៅចំពាក់កណ្តាលផង
ដែលមានរុំព័ទ្ធដោយខ្សែ
-មានម្កុដនៅពីលើយុថ្កាទាំង ២ នេះ

ខ្នាត :-ម្កុដទទឹងខាងក្រោម ១៦មម កំពស់២៨មម
-ទទឹងរូបសញ្ញា ២០មម កំពស់ ៣៤មម
-យុថ្កានិមួយៗប្រវែង២៧មម ទទឹង១៣មម រង្វង់មូល
ដែលមានបន្ទាត់ផ្ចិតខាងក្រៅ ០៣មម ក្នុង១,៥មម
-ដៃយុថ្កាកាត់ទទឹងទំហំ ០១មម ចម្ងាយពីគល់យុថ្កា
៥មម
-ខ្សែចេញពីយុថ្កាទំហំ ០១មម

៦ : សញ្ញាកងអាកាសចរណ៍ខេមរភូមិន្ទ
ដាក់លើហោប៉ៅ



គ្រឿងសំគាល់ :
-រូបម្កុដបំពាក់លើស្លាបសត្វមានកំពស់ ៣២មម
ទទឹង ៥៥មម ប្រវែងពីចុងស្លាបម្ខាងទៅម្ខាង <ខ្ទាស់លើហោ
ប៉ៅអាវខាងស្តាំ >

ខ្នាត : កំពស់ ៣២មម ចុងស្លាបម្ខាងទៅម្ខាង ៥៥មម ។

៧ : សញ្ញាកងអាកាសចរណ៍ខេមរភូមិន្ទ
ដាក់លើហ្លួងសក្តិ



-រូបម្កុដបំពាក់លើស្លាបសត្វមានកំពស់ ២៥មម
ទទឹង ៣៥មុម ប្រវែងពីចុងស្លាបម្ខាងទៅម្ខាង ។
ក -ប៉ាក់លើប៉ានសក្តិស្នា អំពីខ្សែសយពណ៌មាស ឬ
ឆ្លាក់អំពីលោហធាតុ ។

ខ្នាត : កំពស់ ២៧មម ចុងស្លាបម្ខាងទៅម្ខាង ៣០មម ។

៨ : សញ្ញាកងអាកាសចរណ៍ខេមរភូមិន្ទ

ពាក់នៅកអាវសង្ខាង



ខ_ឆ្លាក់អំពីលោហធាតុពណ៌មាស ដោយតភ្ជាប់នៅកអាវសង្ខាង ។

ខ្នាត : កំពស់ ៣០មម ចុងស្លាបម្ខាងទៅម្ខាង ៣៥មម ។

## គ្រឿងសំគាល់សញ្ញាប័ត្រហោះហើរ

៩ : សញ្ញាកងអាកាសយានិកអាកាសចរ

សំគាល់សញ្ញាប័ត្រហោះហើរ

-រូបភាព : សត្វហង្សកាងស្លាបឈរក្នុងរង្វង់មូល មានក្បាច់សម័យអង្គរស្លឹកបីជាន់ ចងខ្សែបូផ្នែកខាងក្រោមទងស្លឹកចងជាប់គ្នាផ្នែកលើក្បាលសត្វហង្ស ។

១_ជើងទាំងពីរសត្វហង្ស ឈរធម្មតាជាគ្រឿងសំគាល់អ្នកបរយន្តហោះ ។

-ខ្នាត : រង្វង់ក្បាច់អង្គរខាងក្រៅ ៤០មម ចុងស្លាបម្ខាងទៅម្ខាង ៦០មម ។



១.អ្នកបើកបរយន្តហោះ



២.យន្តការីហោះហើរ

២_ជើងទាំងពីរសត្វហង្ស ឈរលើស្ពឺចក្រជាគ្រឿងយន្តការីហោះហើរ ។

ខ្នាត : ដូចខាងលើ ។



៣.បុគ្គលិកបង្ហាញផ្លូវ

៣_ជើងទាំងពីរសត្វហង្ស ឈរលើផែនដី ជាគ្រឿងសំគាល់បុគ្គលិក បើកបរ ។

ខ្នាត : ដូចខាងលើ ។



៤.បុគ្គលិកវិទ្យុនិងបង្ហាញផ្លូវ

៤_ជើងទាំងពីរសត្វហង្ស ឈរលើផែនដីមានសញ្ញាផ្លេកបន្ទោរកាត់ ជាគ្រឿងសំគាល់ភ្នាក់ងារវិទ្យុក្នុងអាកាសយាន ។

ខ្នាត : ដូចខាងលើ ។

១០ : សញ្ញាដឹកជញ្ជូនគ្រប់ប្រភេទ



រូបភាព : មានរូបស្ពឺចក្របង្កើតបានជាសញ្ញាគ្រឿងចក្រ នៅចំកណ្តាលមានរូបស្លាបសត្វ ផលិតពីលោហធាតុពណ៌មាស ស្លាបសត្វពណ៌ប្រាក់ កំរាស់ ១,៥មម ។

ខ្នាត : រង្វង់បន្ទាត់ផ្ចិតខាងក្រៅ ៣៥មម ខាងក្នុង ២៦មម កាំបណ្តុះជុំវិញរង្វង់ចំនួន១៦ធ្មេញបណ្តុះចេញពីរង្វង់ខាងក្រៅ ២មម ប្រវែងឃ្លាតពីមួយទៅមួយ ២មម ។ កាំរបស់ចង្កូតចំនួន ៨ ចង្អុលប្រាំបីទិស នៅកណ្តាលស្លាបសត្វប្រវែងបណ្តោយ ១៦មម កំពស់ ១០មម ស្លាបមានពីរជាន់ មួយជាន់ៗមាន ៦ស្លាប ។

១១ : សញ្ញាកងចលនួបត្ថម្ភនិងសំភារៈ



រូបភាព : មានរូបក្អមនៅខាងលើមានអណ្តាតភ្លើង នៅលើក្អមមានគូរវង្វង់ពងក្រពើ ផលិតពីលោហធាតុពណ៌មាស កំពស់ ១,៥មម ។

ខ្នាត : ក្អមមានរាងជារង្វង់បន្ទាត់ផ្ចិត ១២មម មាត់ក្អម៦មម កំពស់កក្អម ១មម អណ្តាតភ្លើងនៅលើមាន ៤ កំពស់អណ្តាតទីមួយ ២០មម ទីពីរ ១៨មម ទីបី ១៦មម ទីបួន ១៤មម អណ្តាតភ្លើងនិមួយ ៗ ប្រវែងទទឹង ២មម ស្រួចចុងរាងជាអណ្តាតភ្លើង ។

១២ : សញ្ញាសុខាភិបាលយោធា



រូបភាព : មានរូបសញ្ញាលេខបូក នៅសញ្ញាលេខបូកត្រង់ទៅលើមានពស់រុំនៅពីលើ ធ្វើពីលោហធាតុ សញ្ញាលេខបូកពណ៌មាស ពស់ពណ៌ទឹកប្រាក់ ។

ខ្នាត : សញ្ញាលេខបូកនិមួយៗប្រវែង ៣៤មម ទទឹង ១០មម នៅសញ្ញាលេខបូកត្រង់ទៅលើចំកណ្តាល មានឆ្នូតបណ្តោយប្រវែង ៦មម សំរាប់ពស់រុំ ពស់រុំបីជាន់ ក្បាលពស់ដកពីខាងលើកន្ទុយពស់ចុះមកក្រោម ២មម ទទឹង ២មម ។

១៣ : សញ្ញាកងភូមិសាស្ត្រយោធា



រូបភាព : មានរូបផែនទីព្រះរាជាណាចក្រកម្ពុជាពណ៌មាស ក្នុងទន្លេមានសាប ទន្លេមេគង្គនៅខាងលើផែនទីមានរូបកុំប៉ាបញ្ឈរពណ៌ប្រាក់ ផលិតពីលោហធាតុ ។

ខ្នាត : ទំហំផែនទីទទឹងប្រវែង ៣០មម កំពស់២៤មម កំពស់កុំប៉ា ៣០មម មុំរបស់ចុងកុំប៉ាបើកចេញពីគ្នា ៥០ អង្សា ចុងកុំប៉ាមួយទៅមួយ២០មម គល់កុំប៉ាលើលានហួសផែនទី៤មម ចុងខាងក្រោមលានហួសផែនទី ២មម ។

១៤ : សញ្ញាកងកាំភ្លើងធំនិងការពារដែនអាកាស



រូបភាព : មានកាំជ្រួចបញ្ឈរត្រង់ទៅលើ ហើយមានកាណុងកាំភ្លើងធំពីសម័យដើមខ្វែងគ្នាដាក់ពីលើរូបកាំជ្រួច។ កាណុងខាងឆ្វេងខ្វែងលើខាងស្តាំ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

ខ្នាត : កំពស់កាំជ្រួច ៣៤មម កាណុងកាំភ្លើងធំនិមួយ ៗ ប្រវែង៣៤មម មុំកាណុងកាំភ្លើងធំខ្វែងគ្នាមានទំហំមុំខាងលើ និងខាងក្រោមទំហំ ១១០ អង្សា មុំចំហៀង ៧០ អង្សា ។

១៥ : សញ្ញាកងរថក្រោះ រថពាសដែក



រូបភាព : ដាវខ្វែងគ្នា នៅចំកណ្តាលមានរូបរថក្រោះ មើលពីមុខ និង ត្រចកសេះ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

ខ្នាត : ដាវនិមួយៗប្រវែង ៤២មម "ក្នុងនោះដងដាវ ៨មម" ទទឹងរថក្រោះ ២០មម កំពស់ទាំងកាណុង ១៤មម កំពស់ត្រចកសេះ១៧មម ចុងត្រចកសេះខាងលើមួយទៅមួយ៩មម លើត្រចកសេះមានស្លាមបោះដែកគោលចំនួន ៥ កន្លែង ។

១៦ : សញ្ញាកងបញ្ជូនសារ



រូបភាព : រូបកងចក្រមានស្លាបខាងក្រៅចំនួន ១៦ នៅលើរូបកងចក្រមានរូបសញ្ញាលេកធាតុអាកាស មុខឡើងទៅលើ ចុងងាកមកស្តាំ ២៥ អង្សា ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

ខ្នាត : បន្ទាត់ផ្ចិតកងចក្រខាងក្រៅ ៣៩មម រង្វង់ទី១ ប្រវែង ២០មម ទី២ប្រវែង១៨មម សញ្ញាលេកធាតុអាកាសបណ្តោយប្រវែង ៣៦មម ទទឹងគល់សញ្ញា ៨មម ។

១៧ : សញ្ញាកងវិស្វកម្ម



រូបភាព : មានរូបវិមានឯករាជ្យបញ្ឈរខាងក្រោម មានកាំជណ្ដើរពីរថ្នាក់ ប្រាសាទខាងលើមានថ្នាក់ ៧ជាន់ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

ខ្នាត : កំពស់ ៣២មម បាតក្រោម ១៦មម តួកណ្ដាល ១២មម ថ្នាក់ក្បាច់ទី១ បន្ទាប់ពីតួកណ្ដាល ១៤មម ។

១៨ : សញ្ញាកងឯកភាពសាលា



រូបភាព : មានព្រះខ័ន្ធខ្វែងជាមួយស្លាបសត្វមួយនៅកណ្ដាល មានសៀវភៅមួយបើក ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

ខ្នាត : ព្រះខ័ន្ធប្រវែង ៣៥មម ស្លាបសត្វមួយ ៣៥មម កំរាស់សៀវភៅ ១០មម បណ្ដោយ ១៥មម ផ្ចិតកណ្ដាលសៀវភៅ ១២មម ។

១៩ : សញ្ញាកងឯកភាពតុលាការយោធា



រូបភាព : រូបក្បាច់ចម្លាក់អង្គរព័ទ្ធជុំវិញរាងស្នែងក្របីធំ កណ្ដាលជើងពានទ្រជញ្ជីង និងសន្លឹកសៀវភៅច្បាប់ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

ខ្នាត : បន្ទាត់ផ្ចិតរង្វង់ក្បាច់ចម្លាក់អង្គរខាងក្រៅ ៣៥មម ខាងក្នុង ២៧មម ជើងពាន និងដងជញ្ជីងប្រវែង ២៤មម ដងឆ្កាងជញ្ជីង ១៣មម សន្លឹកសៀវភៅច្បាប់រៀបរាងកងពីលើដងជញ្ជីងតភ្ជាប់កន្លែងចាប់ជញ្ជីង កំពស់ ៥មម ជញ្ជីងបន្តោងចុះ ៦មម ។

២០ : សញ្ញាកងឯកភាពអយ្យការយោធា



រូបភាព : មានរូបជើងពានចំនួនបីផ្ទាក់ទ្រជញ្ជីង ផលិតពីលោហធាតុពណ៌មាស កំរាស់ ១,៥មម ។

ខ្នាត : កំពស់រូបភាព៣០មម បាតជើងពានខាងក្រោម១៦មម បាតជើងពានទី២ប្រវែង ១០មម មាត់ជើងពានទី២ ប្រវែង ២០មម បាតជើងពានទី៣ ប្រវែង ១១មម មាត់លើប្រវែង ១៥មម បង្គោលជញ្ជីង ៩មម ដងជញ្ជីងរាងកោងចុងមានក្បាច់ប្រវែង១៧មម ជញ្ជីងបន្តោងចុះ ៦មម កំពស់ជើងពានទីមួយនិងទីពីរប្រវែង ១៥មម ជើងពានទីបី ៦មម ។

២១ : សញ្ញាកងសិល្បៈ និងវប្បធម៌យោធា



រូបភាព : មានរូបអក្សរភ្លេងពិសមយដើមផលិតពីលោហធាតុពណ៌មាស ។

ខ្នាត : កំពស់រូបភាព ៣៥មម បាតខាងក្រោម ១២មម ទទឹងរូបភាពកណ្តាល ២៧មម ធំនូសកាត់ខាងលើ ២២មម កំរាស់ ១,៥មម ។

## គ្រឿងសំគាល់សញ្ញាប័ត្រកងទ័ពអាកាស

២២ :



រូបភាព : មានរូបប្រាសាទអង្គរវត្តកំពូលបីនៅចំកណ្តាលស្លាបសត្វនៅចំពីលើ នៅចំកណ្តាលមានរូបព្រះខ័ន្តមុខចុះក្រោម នៅកណ្តាលព្រះខ័ន្តមានរូបតួអក្សរ " ឆ "ខាងក្រោមកណ្តាលមានបន្ទោងចុងស្រួចរាងត្រីកោណ ធ្វើពីលោហធាតុ ប្រាសាទអង្គរពណ៌មាស ព្រះខ័ន្ត និងស្លាបសត្វពណ៌ប្រាក់ រំយោលចុងស្រួចចំកណ្តាលចុះក្រោមពណ៌ក្រហមអក្សរ"ឆ"

ពណ៌ខៀវ កំរាស់ ១,៥មម ។

ខ្នាត ៖ កំពស់រូបភាព ៣៧មម ទទឹង ៧០មម ។ បាតប្រាសាទអង្គរវត្តប្រវែង៣២មម កំពស់ប្រាសាទ១៥មម ព្រះខ័ន្ធប្រវែង ២២មម កំពស់អក្សរ "ឆ"១០មម កំពស់ស្លាបសត្វ១៥មម រំយោលចុះក្រោម ១មម ស្លាបពីរជាន់ ជាន់ទីមួយ ១១ ស្លាប ជាន់ទីពីរ ១០ស្លាប ។

១.សញ្ញាកងឯកភាពឆ័ត្រយោង



រូបភាព ៖ មានឆ័ត្រយោងស្លាបសត្វនិងខាងក្រោមក្បាច់ផ្កាភ្ញីទ្រពីខាងក្រោម ផលិតពីលោហធាតុ ឆ័ត្រយោងនិងស្លាបសត្វពណ៌ទឹកប្រាក់ ផ្កាភ្ញីពណ៌មាស កំរាស់ ១,៥មម ។

ខ្នាត ៖ កំពស់រូបភាព ៤៨មម ទទឹង ៨២មម ។ កំពស់ឆ័ត្រយោង ៣៥មម ខ្សែឆ័ត្រ ២១មម ឆ័ត្រប្រវែង ១៤មម ទទឹងឆ័ត្រខាងក្រោម ចុងឆ័ត្រនិងខ្សែចន្លោះគល់ស្លាបខាងលើទាំងពីរប្រវែង ៣០មម គល់ស្លាបខាងលើទាំងពីរប្រវែង ៣០មម គល់ស្លាបខាងលើទៅចុងស្លាបម្ខាងៗប្រវែង២៥មម ក្បាច់ផ្កាភ្ញីខាងក្រោមរង្វង់ស្នែងក្របី ខាងក្រោមផ្កាមួយមានបន្ទាត់ផ្ចិត ១២មម ផ្កាភ្ញីសង្ខាងប្រវែង ២២មម ។

២. សញ្ញាយោធិនឆ័ត្រយោង



រូបភាព ៖ រូបភាពខ្នាតនិងពណ៌មានដូចរបស់ទីពីរ តែបន្ថែមនៅចំកណ្ដាលចំណុចគល់ស្លាបខាងក្រោមមានកងប៊ិរុចូលគ្នា ខាងលើពណ៌ក្រហម ខាងឆ្វេងពណ៌លឿង ខាងស្ដាំពណ៌ខៀវ របៀបរាងមុំចង្កោន បន្ទាត់ផ្ចិតខាងក្រៅ៨មម ខាងក្នុង៦មម ។

៣.សញ្ញាយោធិនគ្រូបង្ហាត់ឆ័ត្រយោង